

# ការពិតនៃថ្នាំបង្ការជំងឺ COVID-19៖ ការមានផ្ទៃពោះ និងការបំបៅកូនដោយទឹកដោះ




## មូលហេតុដែលគួរទទួលចាក់ថ្នាំបង្ការសម្រាប់ជំងឺ COVID-19

- **ការចាក់ថ្នាំបង្ការគឺជាវិធីដ៏ល្អបំផុតដើម្បីការពារទារកដែលទើបនឹងកើតរបស់អ្នក** ប្រឆាំងនឹងបញ្ហាសុខភាពកម្រិតធ្ងន់ធ្ងរនានាដោយសារជំងឺ COVID-19។ នៅពេលអ្នកបានចាក់ថ្នាំបង្ការរួចហើយនោះ អ្នកបញ្ជូនប្រព័ន្ធការពារប្រឆាំងនឹងជំងឺ COVID-19 ទៅដល់ទារករបស់អ្នក សូម្បីតែមុនពេលពួកគេកើតមកទៀតផង។
- **ការចាក់ថ្នាំបង្ការកាត់បន្ថយហានិភ័យរបស់អ្នកពីការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 ក្នុងអំឡុងពេលមានផ្ទៃពោះ។** អ្នកដែលមានផ្ទៃពោះហើយដែលមានជំងឺ COVID-19 កាន់តែទំនងជានឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរ និងត្រូវសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬត្រូវសម្រាលកូនមុនថ្ងៃ ជាងអ្នកដែលមិនមានជំងឺ COVID-19។



- **ថ្នាំបង្ការជំងឺ COVID-19 ត្រូវបានធ្វើឱ្យថ្មីឡើងវិញ ដើម្បីការពារប្រឆាំងនឹងពូជមេរោគ COVID-19 ដែលកំពុងរាតត្បាតនាពេលឥឡូវនេះ។** មានការណែនាំពីអង្គការធំៗទាំងអស់ផ្នែកសុខភាពម្ដាយឱ្យទទួលចាក់ថ្នាំបង្ការក្នុងអំឡុងពេលមានផ្ទៃពោះ និងពេលបំបៅកូនដោយទឹកដោះ។

## ពេលដែលគួរចាក់ថ្នាំបង្ការ

ការធ្វើថ្នាំបង្ការជំងឺ COVID-19 របស់អ្នកនៅតែគ្រប់លក្ខណៈនិងទាន់ពេលវេលា ក្នុងពេលដែលអ្នកមានផ្ទៃពោះគឺជាការសំខាន់។



- អ្នកអាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដែលបានធ្វើឱ្យថ្មីឡើងវិញ (updated COVID-19 vaccine) **នៅគ្រប់ដំណាក់កាលទាំងអស់នៃការមានផ្ទៃពោះ និងនៅពេលដែលអ្នកកំពុងបំបៅកូនដោយទឹកដោះ ផងដែរ។**
- **អ្នកអាចទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ក្នុងពេលតែមួយជាមួយនឹងថ្នាំបង្ការផ្សេងទៀត** ដែលមានការណែនាំឱ្យទទួលចាក់ក្នុងអំឡុងពេលមានផ្ទៃពោះ រួមមានទាំងថ្នាំបង្ការជំងឺគ្រុនផ្ដាសាយធំ (flu) ថ្នាំបង្ការជំងឺតេតាណូស ជំងឺខាន់ស្លាក់ និងជំងឺក្អកមាន់ (Tdap) ហើយនិងថ្នាំបង្ការសម្រាប់មេរោគប្រភេទ syncytial ដែលឆ្លងតាមផ្លូវដង្ហើមរបស់មនុស្ស (RSV) ជាដើម។

## ថ្នាំបង្ការទាំងឡាយគឺមានសុវត្ថិភាពសម្រាប់អ្នកដែលមានផ្ទៃពោះ។

- ការសិក្សាផ្សេងៗ និងការពិនិត្យតាមដានលើផ្នែកសុវត្ថិភាពចំពោះអ្នកដែលបានទទួលចាក់ថ្នាំបង្ការនៅពេលដែលពួកគេមានផ្ទៃពោះ បានបង្ហាញថាមិនមានការកើនឡើងនៃហានិភ័យចំពោះបញ្ហាផ្នែកសុខភាពផ្ទៃពោះ ឬបញ្ហាដែលអាចមានក្រោយទារកសម្រាលហើយ (birth defects) នោះទេ។
- មិនមានថ្នាំបង្ការជំងឺ COVID-19 ណាមួយមានផ្ទុកមេរោគដែលនៅរស់ឡើយ។ ថ្នាំបង្ការទាំងឡាយមិនអាចធ្វើឱ្យអ្នក ឬទារករបស់អ្នកមានជំងឺ COVID-19 ទេ។



ប្រសិនបើអ្នកមានសំណួរនានា សូមពិភាក្សាជាមួយនឹងគ្រូពេទ្យរបស់អ្នក។ អ្នកក៏អាចទូរស័ព្ទទៅកាន់លេខ 1-866-626-6847 ឬផ្ញើសារជាអក្សរទៅកាន់លេខ 855.999.8525 ឬផ្ញើអ៊ីម៉ែលទៅកាន់ ContactUs@mothertobaby.org ឬក៏មានការសន្ទនានៅលើគេហទំព័រ mothertobaby.org/ask-an-expert បានផងដែរ។

## ធានារ៉ាប់រងសុខភាពរបស់អ្នកនឹងចេញថ្លៃចំណាយនៃថ្នាំបង្ការជំងឺ COVID-19 របស់អ្នកជូន។

- ប្រសិនបើអ្នកមិនមានធានារ៉ាប់រង ឬត្រូវការជំនួយក្នុងការស្វែងរកកន្លែងដើម្បីទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 របស់អ្នកនោះ សូមចូលទៅកាន់គេហទំព័រ **publichealth.lacounty.gov/vaccines/** ហើយចុចនៅលើផ្នែក GET VACCINATED (ទទួលចាក់ថ្នាំបង្ការ) ឬក៏ទូរស័ព្ទទៅកាន់លេខ **1-833-540-0473** រវាងម៉ោង 8 ព្រឹក និងម៉ោង 8 យប់។ អ្នកក៏អាចទូរស័ព្ទទៅកាន់លេខ 2-1-1 ឬសាកសួរទៅកាន់គ្រូពេទ្យរបស់អ្នកបានផងដែរ។
- អ្នកនឹងមិនត្រូវបានសាកសួរអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកឡើយ នៅពេលដែលអ្នកទទួលចាក់ថ្នាំបង្ការ។
- ការចាក់ថ្នាំបង្ការនៅតាមផ្ទះក៏អាចរកបានផងដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ VaccinateLACounty.com ហើយចុចនៅលើផ្នែក In-Home Vaccines (ការចាក់ថ្នាំបង្ការនៅតាមផ្ទះ)។